Vol. 2, No. 5 / ខែមករា ឆ្នាំ2026

EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

ព្រឹត្តិបត្រព័ត៌មាន

@ lbusdengage lbschools.net/engage LONG BEACH UNIFIED • SCHOOL • DISTRICT Excellence and Equity



ព្រឹត្តិការណ៍ដ៏សំខាន់មួយ

ជារឿយៗ អ្នកនឹងឃើញម្តាយប្រចាំមន្ទីរអប់រំ LBUSD ម្នាក់ ឈ្មោះ **Maria Loeza** ចូលរួមប្រជុំជាមួយ Parent University, C.A.F.E., DCAC និង DELAC — នេះជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើនដែលមាតាបិតាមានការប្តេជ្ញាចិត្ត អាចគាំទ្រយ៉ាងសកម្មបានចំពោះសិស្សរបស់ពួកគេ និងសហគមន៍សាលារៀននៅទូទាំងមន្ទីរអប់រំ។ Maria គឺជាម្តាយម្នាក់ដែលផ្តល់សំឡេងគាំទ្រចំពោះកូនៗរបស់គាត់ និងជាអ្នកដឹកនាំម្នាក់នៅក្នុងក្រុមមាតាបិតាជាច្រើនចំណែកដែលបង្ហាញជាគំរូ ដូចដែលយើងឃើញជាមួយក្រុមគ្រួសារជាច្រើនទៀតរបស់យើងនោះដែរ។ នៅពេលគាត់មកដល់កន្លែងប្រជុំ គាត់ធ្វើការរាក់ទាក់បុគ្គលិកដោយឱបរឹត និងបង្ហាញទឹកមុខញញឹមដែលបង្កើតជាបរិយាកាសស្វាគមន៍ក្នុងការឆ្លុះបញ្ចាំងទឹកចិត្តជាភាពដៃគូដែលយើងលើកកម្ពស់អំពី។ ដូចជាមាតាបិតាផ្សេងៗទៀតដែរនៅទូទាំងមន្ទីរអប់រំ LBUSD គឺអ្នកស្រី Loeza លើកទឹកចិត្តដល់អ្នកដទៃឱ្យចូលរួមចំណែក និងធ្វើទំនាក់ទំនងជាមួយសាលារៀននៃសិស្សរបស់ពួកគេ។

នៅក្នុងការចុះផ្សាយនេះ

- **C.A.F.E. – មានការលើកផ្តល់ចំណុចសំខាន់ៗក្នុងបទបង្ហាញមួយស្តីអំពីគោលការណ៍ច្បាប់ប្រើទូរស័ព្ទដៃ និងប្រព័ន្ធផ្សព្វផ្សាយសង្គម (ទំព័រ 3)**
- **ព័ត៌មានថ្មីៗអំពីជំរើសវិទ្យាល័យ និងអនុវិទ្យាល័យ (ទំព័រ 3)**
- **វិដេអូ បង្ហាញព័ត៌មានថ្មីៗអំពីថវិកា (ទំព័រ 4)**
- **កាលវិភាគសំរាប់ការប្រជុំរបស់ក្រុមមាតាបិតាជាច្រើនចំណែក (ទំព័រ 2 & 5)**
- **ធនធានផ្សេងៗសំរាប់ក្រុមគ្រួសារ (ទំព័រ 4)**



រួមគ្នា យើងកំពុងតែកសាងអនាគតកាន់តែប្រសើរ - នៅក្នុង និងជាមួយសហគមន៍របស់យើង!

សូមស្វាគមន៍មកកាន់ខែមករា និងការចាប់ផ្តើមឆ្នាំថ្មី។ នេះជាពេលផ្លាស់ប្តូរមួយដែលលើកទឹកចិត្តឱ្យយើងធ្វើការឆ្អែកមើលសិន គិតមើលឡើងវិញ និងសម្លឹងទៅមុខភ្ជាប់ដោយចេតនា ក្នុងវគ្គដែលយើងឈានចូលដល់ពាក់កណ្តាលទីពីរនៃឆ្នាំសិក្សា។ ក្នុងឆ្នាំ2026 សេចក្តីសង្ឃឹមរួមរបស់យើង គឺស្ថិតនៅតែដដែលក្រោមគោលដៅពង្រឹងទំនាក់ទំនង បង្កើតអត្រាចូលរួមកាន់តែខ្ពស់ និងបន្តធ្វើភាពដៃគូជាមួយក្រុមគ្រួសារដែលជាអ្នកផ្តល់អត្ថប្រយោជន៍ចាំបាច់មកលើភាពជោគជ័យរបស់សិស្ស។ ខណៈពេលយើងឈានឆ្ពោះទៅមុខរួមគ្នា គឺយើងធ្វើការផ្តោតមកលើការបង្កើតលទ្ធផលជាបន្តដែលយើងកំពុងតែមាន ការគាំទ្រគ្នាទៅវិញទៅមក និងការអបអរសាទរភាពលូតលាស់ដែលបានទទួលមក។ ដោយផ្អែកមកលើកិច្ចសហការ ការយកចិត្តទុកដាក់ និងការធ្វើទំនាក់ទំនងជាបន្តបន្ទាប់ គឺយើងនៅតែតាំងប្តេជ្ញាចិត្តជាដដែល ដើម្បីបញ្ចប់ឆ្នាំសិក្សា ស្របដោយភាពរឹងមាំ និងដើម្បីបញ្ជាក់ថា សិស្ស និងក្រុមគ្រួសារទាំងអស់ ពិតជាបានទទួលមែននូវភាពស្វាគមន៍ ការផ្តល់តម្លៃមកកាន់ និងការផ្តល់ជំនួយគាំទ្រ។

Dr. Lucy Salazar



ក្រុមសំរាប់ការចូលរួមរបស់មាតាបិតា



ក្រុមមាតាបិតានានា

ក្រៅតែពីកម្មវិធី CAFE គឺក្រុមគ្រួសារអាចចូលរួមក្នុងក្រុមមាតាបិតានានាបាន ដែលបង្កើតចេញពីជំនាញឯកទេស និងបទពិសោធន៍ ដែលពួកគេនាំមកតាមខ្លួន ដោយក្នុងពេលទន្ទឹមគ្នានោះដែរ គឺផ្តល់នូវឱកាសដ៏មានអត្ថន័យសំរាប់ការដឹកនាំ ការរីកចំរើន និងការរៀនសូត្រផងដែរ។ ក្រុមមាតាបិតាទាំងនេះនាំមាតាបិតាឱ្យជួបជុំគ្នា ដើម្បីរៀនសូត្រអំពីគំនិតផ្តួចផ្តើមរបស់មន្ទីរជាច្រើន ចែករំលែកមតិយោបល់ និងសហការគ្នា អំពីមធ្យោបាយក្នុងការជួយជ្រោមជ្រែងដល់សិស្សទាំងអស់។ តាមរយៈការចូលរួមក្នុងក្រុមនេះ គឺមាតាបិតាមិនត្រឹមតែពង្រឹងនូវជំនាញក្នុងការដឹកនាំរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយបង្កើតនូវអនាគតរបស់សាលា និងសហគមន៍នានារបស់យើងផងដែរ។





DISTRICT COMMUNITY ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមាភាគជាតំណាងមាតាបិតាមកពីសាលា LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។ មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគេ។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀតនៅសាលារបស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃព្រហស្បតិ៍ ទី29 ខែមករា នៅវិទ្យាល័យ Browning – ម៉ោង 5:30 ល្ងាច**



SANKOFA PARENT VILLAGE
LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែនិងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកំពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ ការប្រជុំលើកក្រោយ៖ **ថ្ងៃច័ន្ទ ទី12 ខែមករា នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន – 5:30 ល្ងាច**



DISTRICT ENGLISH LEARNER ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) ជាវិធីសំរាប់ឱ្យមាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគេ នៅកំរិតមន្ទីរអប់រំបាន។ តំណាងរបស់ DELAC មាតាបិតាថ្នាក់ដឹកនាំមន្ទីរអប់រំ និងសមាជិកសហគមន៍ចូលរួមក្នុងការប្រជុំទាំងនេះ ជារៀងរាល់ខែ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី3 ខែកុម្ភៈ នៅវិទ្យាល័យ Browning – ម៉ោង 9:30 ព្រឹក**

EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS
LONG BEACH UNIFIED SCHOOL DISTRICT

កម្មវិធីរបស់យើង ត្រូវបានរចនាបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងបីចមានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការរៀបចំផែនការកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី20 ខែមករា នៅវិទ្យាល័យ Browning ក្នុងបន្ទប់ប្រជុំធំ – 5:30 ល្ងាច**

សិក្ខាលាសំរាប់មាតាបិតា
ដើម្បីរៀនសូត្រ រីកចំរើន និងពង្រឹងសិទ្ធិអំណាច រួមជាមួយគ្នា៖ នៅក្នុង និង ជាមួយ សហគមន៍

C.A.F.E.
ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ




ក្នុងការប្រជុំ C.A.F.E. របស់យើងនៅខែធ្នូ គឺមានលោក Chris Itson ដែលជាអ្នកគ្រប់គ្រងកម្មវិធីប្រចាំការិយាល័យប្រព័ន្ធផ្សព្វផ្សាយសង្គម បានមកធ្វើបទបង្ហាញមួយអំពីសុវត្ថិភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ការប្រើទូរស័ព្ទរបស់សិស្ស និងការប្រើអំពើគំរាមតាម អនឡាញ។ មាតាបិតាមានឱកាសរៀនដែរអំពីគោលការណ៍ច្បាប់របស់ក្រុមប្រឹក្សាភិបាលប្រចាំមន្ទីរអប់រំ LBUSD លេខ 5131.8 ស្តីអំពីការទាមទារការយកចិត្តទុកដាក់ឡើងវិញ ដោយកាត់បន្ថយភាពរំខាន និងគាំទ្រចំពោះសុខុមាលភាព។











សូមចូលរួមជាមួយយើងខ្ញុំនៅថ្ងៃសុក្រ ទី16 ខែមករា ឆ្នាំ2026 ម៉ោង 9:30 ព្រឹក នៅ Educare
4840 Lemon Ave., Long Beach, CA 90807

PARENT UNIVERSITY
LONG BEACH UNIFIED SCHOOL DISTRICT




មានវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ដែលបានរចនាបង្កើតឡើង ដើម្បីជួយ និងផ្តល់សិទ្ធិអំណាចដល់ក្រុមគ្រួសារ ឱ្យក្លាយជាដៃគូសហការដ៏ពេញលេញ នៅក្នុងការអប់រំរបស់កូនពួកគេ។ មាតាបិតា និងអ្នកមើលថែរបស់ LBUSD ត្រូវបានស្វាគមន៍ឱ្យចូលរួម។ មានផ្តល់ជូនមធ្យោបាយយានជំនិះ ការមើលថែកុមារ ការជួយធ្វើលំហាត់កិច្ចការផ្ទះ ហើយនិងសេវាបកប្រែភាសា។





សូមចូលរួមជាមួយយើងខ្ញុំនៅថ្ងៃព្រហស្បតិ៍ ទី12 ខែកុម្ភៈ2026 ក្នុងសិក្ខាសាលាមួយស្តីអំពី សុវត្ថិភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច

សិស្ស LBUSD នៅពេលបច្ចុប្បន្ន៖ ការដាក់ពាក្យជ្រើសរើសអនុវិទ្យាល័យ និងសាលាកំរិតថ្នាក់មត្តេយ្យដល់ថ្នាក់ទី8 នឹងបើកទទួលនៅខែមីនា ឆ្នាំ2026។
សិស្សថ្មី និងសិស្សត្រឡប់មក LBUSD វិញ ដែលរស់នៅក្នុង ឡងប៊ីច (គ្មានឈ្មោះរៀនទេនៅពេលសព្វថ្ងៃ)៖ ការចុះឈ្មោះ គឺបើកទទួលនៅថ្ងៃទី8 ខែមករា ឆ្នាំ2026 នឹងតំរូវឱ្យធ្វើតាម មុននឹងអាចបំពេញការដាក់ពាក្យជ្រើសរើសសាលារៀនបាន។





ឈ្មោះសាលា ដែលសិស្សបានទទួលកន្លែងរៀនជាមួយ គឺនឹងតាំងបង្ហាញនៅថ្ងៃទី23 ខែមករា ឆ្នាំ2026។

ថ្ងៃខែសំរាប់ការដាក់ពាក្យជ្រើសរើសវិទ្យាល័យ គឺបានបញ្ចប់ហើយក្នុងពេលឥឡូវ។ សូមបើកមើលក្នុង ParentVUE នៅម៉ោង 4 ល្ងាច នៅថ្ងៃទី23 ខែមករា ឆ្នាំ2026 ដើម្បីស្វែងយល់អំពីវិទ្យាល័យណាដែលសិស្សបានទទួលកន្លែងរៀនជាមួយ។

សារ និង ធនធានព័ត៌មាន របស់ LBUSD



សូមចុចលើរូបភាព ដើម្បីទទួលបាននូវព័ត៌មានបន្ថែម។



ធនធានជាច្រើនសំរាប់ក្រុមគ្រួសារ

មន្ទីរអប់រំ LBUSD បានប្រមូលទុកព័ត៌មានរាយបង្ហាញធនធានដែលមាននៅតាមសហគម៍ ដើម្បីផ្តល់ជូនក្រុមគ្រួសារ។ ពីការធ្វើទំនាក់ទំនងជាមួយសហគមន៍ រហូតដល់ការសិក្សានៅមហាវិទ្យាល័យ និងការចាប់យកមុខអាជីព។ សូមចុច **<u>នៅទីនេះ។</u>**

Community Connections

Early Childhood Education

Learning at Every Age

Reading and Literacy Resources

Family Resources

College, Career and Beyond



សូមចុចលើខិត្តប័ណ្ណ ដើម្បីទទួលធនធានបន្ថែម

ការជួបពិភាក្សាជាមួយសហគមន៍ស្តីអំពីគោលដៅ និងវិធានការទ្រទ្រង់របស់ក្រុមប្រឹក្សាភិបាលអប់រំ

សូមចូលរួមជាមួយយើងខ្ញុំនៅ
ថ្ងៃអង្គារ ទី27 ខែមករា ឆ្នាំ2026 ម៉ោង 6:00-7:30 ល្ងាច ក្នុងការជួបពិភាក្សាលើកទីមួយរបស់យើងជាមួយសហគមន៍ដែលស្តីអំពីគោលដៅ និងវិធានការទ្រទ្រង់របស់ក្រុមប្រឹក្សាភិបាលអប់រំ។
ការប្រជុំនឹងប្រព្រឹត្តទៅនៅ៖

Rancho Los Alamitos
6400 E. Bixby Hill Road,
Long Beach, CA 90815



<u>lbschools.net/budget.</u>



សូមចុចលើខិត្តប័ណ្ណ ដើម្បីទទួលព័ត៌មានបន្ថែម

ព័ត៌មានថ្មីៗក្នុងខែមករាអំពីថវិកា

ខណៈពេលមន្ទីរអប់រំ LBUSD បន្តធ្វើការអនុលោមតាមយុទ្ធសាស្ត្រដើម្បីបង្កើនវត្តមានសិក្សាប្រចាំថ្ងៃរបស់សិស្ស និងការចំណាយតាមការកំណត់ ព័ត៌មានថ្មីៗក្នុងខែមករានឹងផ្តល់បន្ថែមអំពី<u>ផែនការអាទិភាព</u> <u>និងស្ថិរភាពហិរញ្ញវត្ថុ</u> ដែលត្រូវបានលើកបង្ហាញជូនក្រុមប្រឹក្សាភិបាលអប់រំក្នុងខែធ្នូ។
ផែនការអាទិភាព និងស្ថិរភាពហិរញ្ញវត្ថុ ស្វែងរកមធ្យោបាយកាត់បន្ថយថវិកាយ៉ាងតិចបំផុតចំនួន 50 លានដុល្លារ ទាន់មុនពេលចាប់ផ្តើមឆ្នាំសារពើពន្ធ 2026-2027។ ចំនួនកាត់បន្ថយសំរាប់ឆ្នាំ 2026-2027 នឹងប៉ះពាល់ដល់ជាង 60 មុខងាររបស់បុគ្គលិកនៅតាមក្រសួងថ្នាក់លើ រួមបញ្ចូលទាំងមុខងារផ្នែកគ្រប់គ្រង និងមុខងារមិនគ្រប់គ្រង ការកាត់បន្ថយមុខងាររបស់បុគ្គលិកខ្លះនៅតាមសាលារៀន និងការអនុលោមតាមស្តង់ដារបុគ្គលិកដែលសមស្របជាមួយព្យាករណ៍នៃចំនួនសិស្សចុះឈ្មោះរៀន 59,000 នាក់ក្នុងឆ្នាំសិក្សា 2026-27។ ខណៈពេលដែលការកាត់បន្ថយបុគ្គលិកនៅតាមក្រសួងថ្នាក់លើ និងនៅតាមសាលារៀននឹងត្រូវបានទទួលដឹងឮនៅទូទាំងមន្ទីរអប់រំ គឺយើងខ្ញុំក៏យកចិត្តទុកដាក់ផងដែរចំពោះផលប៉ះពាល់ដែលវាអាចមានមកលើសិស្ស ក្រុមគ្រួសារ និងបុគ្គលិករបស់យើង។
ព័ត៌មានថ្មីៗនេះលើកបង្ហាញជំនួយគាំទ្រជាក់លាក់សំខាន់ៗដែលនឹងនៅតែរក្សាទុកសំរាប់ឆ្នាំសិក្សា 2026-2027 ដែលសមស្របតាមគោលការណ៍ណែនាំសំរាប់<u>អាទិភាព និងស្ថិរភាពហិរញ្ញវត្ថុ</u>។ ជំនួយគាំទ្រសំខាន់ៗដូចតទៅនេះនឹងនៅតែមានជាបន្តសំរាប់សិស្សក្នុងពេលដែលយើងឈានចូលដល់ឆ្នាំសិក្សា 2026-2027៖

<u>lbschools.net/budget.</u>



សូមចុចលើរូបភាពនេះ ដើម្បីមើល វីដេអូ

សារដាក់ផ្ញើមកពី
អគ្គនាយក Dr. Jill Baker



សូមចុចលើរូប ដើម្បីមើល វីដេអូ

ព្រឹត្តិការណ៍ជាបន្តបន្ទាប់ និង ឱកាសធ្វើទំនាក់ទំនង

សូមឆែកមើលនៅតាមចំណែកនេះរាល់ខែអំពីសិក្ខាសាលា ការប្រជុំមាតាបិតា និងព្រឹត្តិការណ៍ផ្សេងៗ ដែលនឹងរៀបចំផ្តល់ជូនជាបន្តបន្ទាប់។ សូមកុំភ្លេចអំពីឱកាសរៀន រាក់ទាក់ស្គាល់គ្នា ទទួលការសិក្សា និងធ្វើទំនាក់ទំនងជាមួយសហគមន៍សាលារៀនរបស់យើង។

ខែមករា

S	M	T	W	TH	F	S
				1	2	3
4	5	6 ប្រជុំ DELAC នៅវិទ្យាល័យ Browning 9:30 ព្រឹក	7 ប្រជុំ CAC នៅសាលា Tucker – 6:00 ល្ងាច សិក្ខាសាលា អនឡាញ អំពីកម្មវិធីអប់រំថ្នាក់កុមារដ្ឋាន 6:00 ល្ងាច	8 សិក្ខាសាលា Parent University នៅវិទ្យាល័យ Browning 5:30 ល្ងាច	9	10
11	12 Sankofa នៅ TRC 5:30 សិក្ខាសាលា Parent University អនឡាញ 6:00 ល្ងាច	13	14 ប្រជុំក្រុមប្រឹក្សាភិបាលអប់រំ 5 ល្ងាច	15	16 C.A.F.E. នៅ Educare 9:30 ព្រឹក	17 ក្បួនដង្ហែ MLK Jr.
18	19 ថ្ងៃសំរាក MLK Jr.	20 ប្រជុំ EONA នៅវិទ្យាល័យ Browning 5:30 ល្ងាច	21	22	23	24
25	26	27 ការជួបពិភាក្សាជាមួយសហគមន៍ 6:00 ល្ងាច	28	29 ប្រជុំ DCAC នៅវិទ្យាល័យ Browning 5:30-6:30 ល្ងាច	30	31

Parent University



C.A.F.E.



DCAC



EONA



DELAC

